ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៤ លេខ ២០ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

ក

មាតិកា

I - ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៨-២-១៩៩៦	ព្រះរាជក្រឹត្យ ជស/រកត/០២៩៦/០៩ តែងតាំងឥស្សរជន ជាទីប្រឹក្សាផ្ទាល់សម្តេច ជា ស៊ុម	៨៣៧
១០-៥-១៩៩៦	ព្រះរាជក្រឹត្យ ជស/រកត/០៥៩៦/១៩ តែងតាំងឯកឧត្តម ហោ ណាំបូរ៉ា ជាទីប្រឹក្សាផ្ទាល់ផ្នែកទំនាក់ទំនងអន្តរជាតិរបស់ សម្តេច ជា ស៊ុម	៨៣៨
២០-៥-១៩៩៦	ព្រះរាជក្រឹត្យ ជស/រកត/០៥៩៦/២៣ តែងតាំងលោកឧត្តម សេនិយ៍ត្រី កែវ ពង្ស ជាមេបញ្ជាការរងយោធភូមិភាគទី ៣	៨៣៩

II - ទីស្តីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

២៨-៥-១៩៩៦	អនុក្រឹត្យលេខ ៩៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៨៤០
២៨-៥-១៩៩៦	អនុក្រឹត្យលេខ ៩៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៨៤២
២៨-៥-១៩៩៦	អនុក្រឹត្យលេខ ៩៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៨៤៣
២៨-៥-១៩៩៦	អនុក្រឹត្យលេខ ៩៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៨៤៥
២៨-៥-១៩៩៦	អនុក្រឹត្យលេខ ៩៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៨៤៦
២៩-៥-១៩៩៦	អនុក្រឹត្យលេខ ៩៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	៨៤៧
២៩-៥-១៩៩៦	អនុក្រឹត្យលេខ ៩៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	៨៤៨
៣០-៥-១៩៩៦	អនុក្រឹត្យលេខ ១០០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៨៤៩
៣០-៥-១៩៩៦	អនុក្រឹត្យលេខ ១០១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៨៥០
៣០-៥-១៩៩៦	អនុក្រឹត្យលេខ ១០២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៨៥១

២ - សេចក្ដីសំរេច

២៨-៥-១៩៩៦	សេចក្ដីសំរេចលេខ ១៨ សសរ ស្ដីពីការបង្កើតគណៈកម្មការពិសេសសំរាប់ពិនិត្យបញ្ជីហិរញ្ញវត្ថុរបស់ធនាគារកណ្ដាល	៨៥៣
២៩-៥-១៩៩៦	សេចក្ដីសំរេចលេខ ១៩ សសរ ស្ដីពីការប្រគល់ភារកិច្ចបណ្ដោះអាសន្ន	៨៥៥

៣ - សារាចរ

៣០-៥-១៩៩៦	សារាចរលេខ ០៤ សរ ស្ដីពីការរក្សាសណ្ដាប់ធ្នាប់របៀបរបបនៅពេលប្រឡង	៨៥៦

III - ការងារបណ្ដាក្រសួង

១ - ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

៣០-៥-១៩៩៦	ប្រកាសលេខ ៣៥៩ បល.ប្រក ស្ដីពីការផ្ទេរនិងតែងតាំងមន្ត្រីរាជការ	៨៥៨

២ - ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

២៧-៥-១៩៩៦	ប្រកាសលេខ ១៨៥ ពណ.គន.ប្រក ស្ដីពីការប្រគល់ទីតាំងមណ្ឌលឃ្លាំងលេខ ១	៨៦០
២៧-៥-១៩៩៦	ប្រកាសលេខ ១៨៦ ពណ.គន.ប្រក ស្ដីពីការប្រគល់ឃ្លាំងដូនម៉ៅ (កំពង់ចាម)	៨៦១
២៧-៥-១៩៩៦	ប្រកាសលេខ ១៨៧ ពណ.គន.ប្រក ស្ដីពីការប្រគល់ដី និងឃ្លាំងបេតុងត្រើយខាងកើតកំពង់ចម្លងអ្នកលឿង	៨៦២

៣ - ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

២៧-៥-១៩៩៦ ប្រកាសលេខ ១៣៩/៩៦ ពម.មសទ.ប្រក អនុញ្ញាតជូនលោក ខូវ ស្រៀង បើកអាជីវកម្មរោងពុម្ពឈ្មោះ « សុភមង្គល » ៨៦៤

៤ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

២៤-៥-១៩៩៦ ប្រកាសលេខ ៤១២ អយក.ប្រក ស្តីពីការអនុញ្ញាតឱ្យបោះពុម្ព សៀវភៅសំរាប់គ្រូ « គណិតវិទ្យា ថ្នាក់ទី ១ » ៨៦៥

២៤-៥-១៩៩៦ ប្រកាសលេខ ៤១៣ អយក.ប្រក ស្តីពីការអនុញ្ញាតឱ្យបោះពុម្ព សៀវភៅសំរាប់គ្រូ « ភាសាខ្មែរ ថ្នាក់ទី ១ » ៨៦៧

២៨-៥-១៩៩៦ ប្រកាសលេខ ៤១៦ អយក.ប្រក ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យ ក្រាំងយ៉ូវ ទៅជាអនុវិទ្យាល័យ «ហ៊ុន សែន ក្រាំងយ៉ូវ » ស្ថិតនៅ ក្នុងស្រុកស្អាងខេត្តកណ្តាល ៨៦៨

៥ - ទីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

២៤-៥-១៩៩៦ ប្រកាសលេខ ៨៩ ប្រក.វវស.ប ស្តីពីការបង្កើតគណៈកម្មាធិការ បច្ចេកទេសរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីកែទំរង់ រដ្ឋបាល ៨៧០

២៧-៥-១៩៩៦ ប្រកាសលេខ ៩០ ប្រក.វវស.ប ស្តីពីការផ្ទេរបណ្ណាល័យជាតិ និង ក្របខ័ណ្ឌមន្ត្រីរាជការ ៨៧២

២៩-៥-១៩៩៦ ប្រកាសលេខ ៩២ ប្រក.វវស.ប ស្តីពីការបង្កើតគណៈកម្មការ មេប្រយោគប្រឡងយកសញ្ញាបត្រសិល្បៈ និងស្នាតកបត្រសិល្បៈ ៨៧៥

I - ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ ជស/រកត/០២៩៦/០៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមសេចក្តីសំរេចរបស់រដ្ឋសភាស្តីពីការជ្រើសរើសតាំងសម្តេច **ជា ស៊ីម** ជាប្រធាន រដ្ឋសភា នាសម័យប្រជុំពេញអង្គលើកទី ១ និតិកាលទី ១ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៣
- យោងតាមសំណើរបស់ប្រធានរដ្ឋសភា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឥស្សរជនដូចមានរាយនាមខាងក្រោមនេះ ជាទីប្រឹក្សាផ្ទាល់ ផ្នែកកិច្ចការយោធា សន្តិសុខ សេដ្ឋកិច្ច វប្បធម៌ សង្គមកិច្ច របស់សម្តេច **ជា ស៊ីម** ប្រធានរដ្ឋសភានៃព្រះ រាជាណាចក្រកម្ពុជា បន្ថែមលើភារកិច្ចបច្ចុប្បន្ន ដោយមានឋានៈស្មើនឹងអនុរដ្ឋលេខាធិការ ៖

១–ឯកឧត្តម **ម៉េង ឆាត់**

២–ឯកឧត្តម **នុត ថុន**

៣–ឯកឧត្តម **អ៊ុន ជែន**

៤–ឯកឧត្តម **លី គឹមហាន**

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងអគ្គលេខាធិការរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ជស/រកត/០៥៩៦/១៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមសេចក្តីសំរេចរបស់រដ្ឋសភាស្តីពីការជ្រើសរើសតាំងសម្តេច **ជា ស៊ីម** ជាប្រធាន.រដ្ឋសភា នាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ១ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៣
- យោងតាមសំណើរបស់ប្រធានរដ្ឋសភា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ហោ ណាំបូរ៉ា** ជាទីប្រឹក្សាផ្ទាល់ផ្នែកទំនាក់ទំនងអន្តរជាតិរបស់សម្តេច **ជា ស៊ីម** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ដោយមាន

ឋានៈស្មើនឹងអនុរដ្ឋលេខាធិការ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងអគ្គលេខាធិការរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ជស/រកត/០៥៩៦/២៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- ព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែ

សំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
– យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា .

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឋានន្តរស័ក្តិនាយទាហានជាន់ខ្ពស់ថ្នាក់ ឧត្តមសេនីយ៍ត្រី ក្នុងកងយោធពលខេមរភូមិន្ទចំពោះលោក ÷
– កែវ ពន្ធ ជាមេបញ្ជាការរង យោធភូមិភាគទី ៣

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា និងសហអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសម្រេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៩៦
ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា
ជា ស៊ីម

* * *

II - ទីស្តីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ៩៣ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់អភិបាលខេត្តក្រចេះ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ មាស ស្ថាបនាជាតិ ជូនចំពោះលោក **ឡេង ឫទ្ធី** ប្រធានក្រុមហ៊ុន ឫទ្ធី មិចកូ ដែលបានជួយជួសជុលផ្លូវជាតិលេខ ១៣ ប្រវែង ១៥,៨០០ គីឡូម៉ែត្រ ពីស្រុកស្នួល ខេត្តក្រចេះ ដល់ព្រំដែនប្រទេសវៀតណាម អស់ទឹកប្រាក់សរុប ១៨៨.០០០ ដុល្លារ សហរដ្ឋ អាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាល ខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ៩៤ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រ កម្ពុជា
- តាមសំណើររបស់រដ្ឋមន្ត្រីប្រតិភូទទួលបន្ទុកគ្រប់គ្រងយុវនីតិសម្បទា

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាសស្ថាបនាជាតិ តាមលំដាប់ថ្នាក់ជូនចំពោះសប្បុរសជនដែលមានសទ្ធាជ្រះថ្លាបានជួយរិភាគទានដើម្បីអភិវឌ្ឍន៍ ស្ថាប័នយុវនីតិសម្បទាដូចមានរាយនាមខាងក្រោមនេះ ÷

ក - មេដាយមាស

១–លោក TONY TANDIJONO ក្រុមហ៊ុន Holiday International ទឹកប្រាក់ ៣០.០០០$ ។

២–លោកវេជ្ជបណ្ឌិត YOUN KEUN CHA ប្រធានមូលនិធិសុខុមាលភាពកូរ៉េទឹកប្រាក់ ២៥.៣០២ $ ។

៣–លោក **ម៉ែន សារ៉ុន** ប្រធានក្រុមហ៊ុន ម៉ែន សារ៉ុន ទឹកប្រាក់ ២៤.០០០$

៤–លោក **សេង គាន់ឆឹង** ប្រធានក្រុមហ៊ុនអង្គរអភិវឌ្ឍន៍ជំណាំឧស្សាហកម្មទឹកប្រាក់ ១៥.០០០$

៥–លោក **នាយ អេង** ប្រធានក្រុមហ៊ុន POLICO ទឹកប្រាក់ ១៥.០០០$ ។

៦–លោក ALEX THIAGARASAN ប្រធានក្រុមហ៊ុន ZETAVEST ទឹកប្រាក់ ១៣.០០០$

៧–លោកឧកញ៉ា **សុខ គង់** ប្រធានក្រុមហ៊ុន SOKIMEX ទឹកប្រាក់ ១០.០០០$

៨–លោក **ជីង សុភាព** ប្រធានក្រុមហ៊ុនភាពីម៉ិច ទឹកប្រាក់ ១០.០០០$

៩–លោកស្រី **ស៊ាម ឈុនហេង** ប្រធានក្រុមហ៊ុន សាហេងម៉ិចកូ ទឹកប្រាក់ ១០.០០០$

ខ - មេដាយប្រាក់ :

១–លោក **ម៉ុង ឫទ្ធី** ប្រធានក្រុមហ៊ុន ម៉ុង ឫទ្ធី ទឹកប្រាក់ ៧.១៤៩$

២–លោក **ឆា សាគុណ** ក្រុមហ៊ុន PELICO ទឹកប្រាក់ ៥.០០០$

គ - មេដាយសំរឹទ្ធ :

១–លោក **ស្រី មុល្លី** ប្រធានក្រុមហ៊ុន មុល្លី ទឹកប្រាក់ ១.០០០$

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ៩៥ អនក្រ.គត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់គណៈកម្មការអាចារ្យវត្ត មជ្ឈិមសរារាម

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិ ប្រគេនជូនចំពោះព្រះចៅអធិការ និងសប្បុរសជនដែលបានជួយកសាង សាលារៀន ព្រះវិហារ ផ្លូវលំ ស្រះទឹក របង ក្លោងទ្វារ សាលា ឆាន់ និង ម៉ាស៊ីនភ្លើងនៅក្នុងវត្ត មជ្ឈិមសរារាម ហៅវត្តជ្រឹង ក្នុងឃុំរការកោងទី ១ ស្រុកមុខកំពូល ខេត្តកណ្តាល ដូចមានរាយព្រះនាម និង នាមខាងក្រោម ÷

១-ព្រះគ្រូ **គិន ប៊ុនស្រៀ**	ចៅអធិការវត្តមជ្ឈិមសរារាម
២-លោក **ម៉ោញ សំអាត**	នៅភ្នំពេញ បរិច្ចាគប្រាក់ ២០.០០០$
៣-លោក **អាន់ឌើសុន ឌី**	ហៅសារុន នៅសហរដ្ឋអាមេរិក បរិច្ចាគប្រាក់ ១៥.០០០$

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋលេខាធិការ នៃក្រសួងធម្មការ និងសាសនា និង អភិបាលខេត្តកណ្តាល

ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ៩៦ អនក្រ.តក

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិជូនលោក **ម៉ៃ ឧុទ្ធី** នាយកក្រុមហ៊ុន វុទ្ធីពាណិជ្ជ ដែលបានជួយកសាងសំណង់សាធារណៈផ្សេងៗ ដូចសាលារៀន មន្ទីរពេទ្យ មន្ទីរកាកបាទ ក្រហម និង ជួយឧបត្ថម្ភដល់មជ្ឈមណ្ឌលកុមារកំព្រានៅក្នុងខេត្ត កោះកុង អស់ទឹកប្រាក់ សរុប

១០២.៦០០$ ដុល្លារសហរដ្ឋអាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកោះកុង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ៩៧ អនក្រ.គត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិជូនសប្បុរសជនខ្មែរ រស់នៅប្រទេសបារាំង ចំនួន ០២ រូប ដែលបានបរិច្ចាគ ទ្រព្យសម្បត្តិផ្ទាល់ខ្លួនចូលរួមកសាងសមិទ្ធផល សាធារណៈនៅក្នុងខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោម :

១-លោក **តាន់ ឈុន** បានជួយធ្វើផ្លូវក្នុងក្រុងបាត់ដំបងអស់ទឹកប្រាក់ ១០៥.៦៦៥ $US

២-លោក **តាំង ករាំង** បានជួយកសាងរង្វង់មូល និង រូបសំណាក់ព្រះនរាយណ៍អស់ទឹកប្រាក់ ២៥.៧៦៨,៥០ $US

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ៩៨ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

សំរេច

មាត្រា ១ : តែងតាំងលោក **ស៊ុយ សេរិន្ទ** ជំនួយការឯកឧត្តម រស់ សម័យ ទីប្រឹក្សាអមសម្តេចនាយក រដ្ឋមន្ត្រីទី ១ មានឋានៈស្មើប្រធាននាយកដ្ឋាន ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង ស្ថាប័នដែល ពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ៩៩ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– យោងតាមសំណើសហរដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី

សំរេច

មាត្រា ១ : តែងតាំងលោក **ហង្ស ឆាំឆាន** ជំនួយការឯកឧត្តម សោម ចិន ទីប្រឹក្សាអមសម្តេចនាយករដ្ឋមន្ត្រីទី ២ មានឋានៈស្មើប្រធាននាយកដ្ឋាន ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង ស្ថាប័នដែល ពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្ត អនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ១០០ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស

នៃព្រះរាជាណាចក្រកម្ពុជា

- យោងតាមសំណើរបស់អភិបាលខេត្តកំពង់ស្ពឺ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិជូនចំពោះសប្បុរសជន ០២ រូប ដែលបានបរិច្ចាគថវិកា ចំនួន ៥០.២០០ ដុល្លារអាមេរិក សំរាប់កសាងកុដិមួយ ខ្នងនៅក្នុងវត្តកលព្រឹក្ស ហៅវត្តជជ្រុក ក្នុងឃុំជជ្រុក ស្រុកគងពិសី ខេត្ត កំពង់ស្ពឺ ដូចមានរាយនាមខាងក្រោម ÷

១-ឯកឧត្តម ឧត្តមនាវិត្រី **ឡៅ វិញ**

២-លោកជំទាវ **ចំរេន្ទ្រា ឡៅវិញ**

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋលេខាធិការ នៃក្រសួងធម្មការ និង សាសនា និងអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះអោយ ទទួលលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ១០១ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាស អោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់នាយកមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពត

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ មាស ស្ថាបនាជាតិជូនចំពោះសប្បុរសជនដែលមានសទ្ធាជ្រះថ្លា បានបរិច្ចាគថវិកាផ្ទាល់ខ្លួនសំរាប់សាងសង់អាគារសិក្សា០១ខ្នងដោយ មានបំពាក់សង្ហារឹម សិក្សាគ្រប់គ្រាន់ និង ចែកអំណោយជូនសិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ នៅក្នុង ខេត្តកំពត អស់ទឹកប្រាក់សរុប ៦៥.៣៩៦.៣២០ រៀលដូចមានរាយព្រះនាម និង នាមខាងក្រោម នេះ ។

១-ឯកឧត្តម **យុត ចន្ថា** និង លោកជំទាវ **នាង សម្បត្តិ**

២-ព្រះតេជគុណ **ណយ ច្រឹក**

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ១០២ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់គណៈកម្មការអាចារ្យវត្តចំណោម

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិតាមលំដាប់ថ្នាក់ប្រគេន និង ជូនចំពោះសប្បុរសជន ខ្មែររស់នៅសហរដ្ឋអាមេរិក ដែលមានសទ្ធាជ្រះថ្លា បានបរិច្ចាគធនធានជួយកសាង ព្រះវិហារនៅវត្តចំណោម ឃុំចំណោម ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដូចមានរាយព្រះនាម និង នាមខាងក្រោម ÷

ក–មេដាយមាស :

១–លោក **ឆាន ឡឿន** និង លោកស្រី **អ៊ឹម រិត** បរិច្ចាគប្រាក់ចំនួន ២៣.៨៦០ $US

ខ–មេដាយប្រាក់ :

១–លោក **ម៉ុក ចឿន** អ្នកស្រី **ញាន ឈឿម** និងយុវជន **ជុំ ខោល** បរិច្ចាគប្រាក់ ៦.៨៧៨ $US

គ–មេដាយសំរិទ្ធ :

១–ព្រះតេជគុណ **សំសក់ សំគិន** បរិច្ចាគប្រាក់ ៣.៦០០ $US

២–ព្រះគ្រូ បរិត្ត **កោសល** បរិច្ចាគប្រាក់ ៣.៦០០$ US

៣–លោក **ស៊ុម ឈឿន** អ្នកស្រី **ឡី ទី** បរិច្ចាគប្រាក់ ៣.៥០០$ US

៤–អ្នកស្រី **ម៉ែន ឡាក់** បរិច្ចាគប្រាក់ ៣.៤៨១$ US

៥–លោក **ម៉ឺន គង់** អ្នកស្រី **ហេង ស៊ី** បរិច្ចាគ ៣.០៥០$ US

៦–លោក **ឈុំ ហ៊ុន** អ្នកស្រី **ប៊ូ កែវ** បរិច្ចាគប្រាក់ ១.៣០០$ US

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋលេខាធិការ ក្រសួងធម្មការ និង សាសនា និង អភិបាលខេត្ត បន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

២ - សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ ១៤ សសរ

ស្តីពីការបង្កើតគណៈកម្មការពិសេសសំរាប់

ពិនិត្យបញ្ជីហិរញ្ញវត្ថុ របស់ធនាគារកណ្តាល

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ .
- បានឃើញច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ចុះ ថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៩៦
ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ នស.រកម ០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ .
- យោងតាមសំណើរបស់ ឯកឧត្តមអគ្គទេសាភិបាលធនាគារជាតិ នៃកម្ពុជា

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការពិសេសមួយ សំរាប់ត្រួតពិនិត្យបញ្ជីហិរញ្ញវត្ថុរបស់ធនាគារកណ្តាល ដែលមានសមាសភាពដូចតទៅ :

១–តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាន
២–តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក
៣–តំណាងអធិការកិច្ចរាជរដ្ឋាភិបាល សមាជិក.

ប្រការ ២ : គណៈកម្មការពិសេសនេះមាននាទីជាសវនការគណនី និង មានភារកិច្ចធ្វើរបាយការណ៍ប្រចាំឆ្នាំពីរប្រភេទ គឺ :

–របាយការណ៍ទូទៅ
–របាយការណ៍ពិសេស

ប្រការ ៣ : របាយការណ៍ទូទៅ ជារបាយការណ៍ស្តីអំពីលទ្ធផលត្រួតពិនិត្យការចុះបញ្ជីក្នុងសៀវភៅត្រឹមត្រូវ ឬ មិនត្រឹមត្រូវតាមខ្នងគណនី នៃធនាគារកណ្តាល ។

ប្រការ ៤ : របាយការណ៍ពិសេស ជាសេចក្តីអត្ថាធិប្បាយលើរាល់កិច្ចការសន្យារវាងធនាគារកណ្តាល និងស្ថាប័នធនាគារនានា ឬ និង ស្ថាប័នហិរញ្ញវត្ថុកណ្តាល ឬ ថ្នាក់ដឹកនាំធនាគារកណ្តាលមានភាគហ៊ុន ។

ប្រការ ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា និង សាមីខ្លួនក្នុងប្រការ

១ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្ថលេខា និង ត្រា ហត្ថលេខា និង ត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ ១៩ សសរ

ស្តីពីការប្រគល់ភារកិច្ចបណ្តោះអាសន្ន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- ផ្អែកតាមការចាំបាច់ ។

សំរេច

ប្រការ ១ : ប្រគល់ភារកិច្ចជូនឯកឧត្តម **ស៊ុំ ម៉ាន់ិត** រដ្ឋលេខាធិការទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជារដ្ឋមន្ត្រីស្តីទី ក្រសួងផែនការ ចាប់ពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៦ រហូតដល់ថ្ងៃ ឯកឧត្តម **ជា ចាន់តូ** ត្រឡប់មកពីបំពេញបេសកកម្មនៅឯបរទេសវិញ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និង

ឯកឧត្តមដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្ដីសំរេច ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

៣ - សារាចរ

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៦

សារាចរស្ដីពីការរក្សាសណ្ដាប់ធ្នាប់ របៀបរៀបរយនៅពេលប្រលង

នៅដំណាច់ឆ្នាំសិក្សា ១៩៩៥–៩៦ នេះ នៅទូទាំងប្រទេស និងមានរៀបចំប្រលងបញ្ចប់គ្រប់ ភូមិសិក្សាផ្នែកចំណេះទូទៅ និងបំពេញវិជ្ជាតាមកាលបរិច្ឆេទដូចតទៅ ÷

- ប្រលងវិញ្ញាបនប័ត្របឋមសិក្សា ថ្ងៃទី ១៣ កក្កដា ១៩៩៦
- ប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត១ លើកទី១ ថ្ងៃទី ០១ កក្កដា ១៩៩៦ និងថ្ងៃបន្តបន្ទាប់
- ប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត១ លើកទី២ ថ្ងៃទី១៩ សីហា ១៩៩៦ និងថ្ងៃបន្តបន្ទាប់
- ប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត២ លើកទី១ ថ្ងៃទី១០ មិថុនា ១៩៩៦ និងថ្ងៃបន្តបន្ទាប់
- ប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត២ លើកទី២ ថ្ងៃទី ២២ កក្កដា ១៩៩៦ និងថ្ងៃបន្តបន្ទាប់

កន្លងមកការរៀបចំប្រលង ទទួលបានលទ្ធផលល្អមួយកំរិតធំហើយ ប្រៀបធៀប និង លទ្ធភាពដែលយើងមាន និងសភាពការណ៍ជាក់ស្ដែង នៃព្រះរាជាណាចក្រកម្ពុជាយើង តែក៏នៅមាន ចំណុចសេសសល់ខ្លះៗដែលចាំបាច់ត្រូវកែលំអដូចជា :

- ការបង្កភាពអនាធិបតេយ្យខាងការប្រលង
- ការថតចំលងចំលើយវិញ្ញាសា លក់តគ្រឹកគគ្រេងជុំវិញមណ្ឌលប្រលង
- ចាតុភាពគប់ និងបោះសំដៅចូលបន្ទប់ប្រលង
- ការរត់សំរុកចូល ក្នុងមណ្ឌលប្រលងយកសំណៅអោយបេក្ខជន
- ការគំរាមកំហែងគណៈមេប្រយោគ

អាស្រ័យហេតុនេះ ដើម្បីអោយការប្រលងនៅដំណាច់ឆ្នាំសិក្សា ១៩៩៥-៩៦ នេះប្រព្រឹត្តទៅក្នុងភាពប្រក្រតីមានសណ្តាប់ធ្នាប់របៀបរៀបរយល្អធានាបានភាពយុត្តិធម៌ ស្អាតស្អំជូនបេក្ខជន និងមាតា បិតា ឬអាណាព្យាបាលបេក្ខជននោះ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចតទៅ ÷

១-គ្រប់ក្រសួង និងគ្រប់ខេត្ត-ក្រុងត្រូវចាត់តាំងអប់រំអោយបានទូលំទូលាយជូនមន្ត្រី រាជការ បុគ្គលិក កម្មករ ប្រជារាស្ត្រទូទាំងក្រសួង ស្ថាប័ន និង ខេត្ត-ក្រុង អោយយល់ពីលក្ខការណ៍នៃការប្រលងដែលផ្សព្វផ្សាយដោយក្រសួងអប់រំ យុវជន និង កីឡា ដើម្បីចៀសវាងការអនុវត្តនូវប្រការណាមួយផ្ទុយ និងបទបញ្ញត្តិ នៃការប្រលង ឬធ្វើអោយខូចសណ្តាប់ធ្នាប់របៀបរៀបរយ បង្កើតភាពស្មុគ្រស្មាញ ក្នុងពេលប្រលង ។ សូមណែនាំអប់រំបងប្អូន កូនចៅទាំងអស់អោយមានស្មារតីនឹងន និងទុកចិត្តថា រាជរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា នឹងយកចិត្តទុកដាក់ទទួលខុសត្រូវចំពោះការរៀបចំប្រលងអោយបានល្អប្រសើរជូនមាតាបិតា អាណាព្យាបាលសិស្ស និង សិស្សានុសិស្សទាំងអស់ ។ សូមបញ្ឈប់ជាដាច់ខាតនូវការធ្វើអន្តរាគមន៍ និង ស្ទូកច៉ាន់គណៈមេប្រយោគ ដើម្បីអោយកូនចៅ ឬកូនក្មួយរបស់ខ្លួនបានប្រលងជាប់ដែលផ្ទុយ នឹងភាពយុត្តិធម៌ និងសមត្ថភាពសាមីខ្លួន ។

២-ចំពោះលោកគ្រូ អ្នកគ្រូ ដែលជាគណៈមេប្រយោគ និងមន្ត្រីរាជការដែលមានភារកិច្ចទទួលខុសត្រូវក្នុងការងារប្រលង និង នគរបាល កងអាវុធហត្ថ ដែលមានភារកិច្ចសហការ រក្សាការពារ សណ្តាប់ធ្នាប់ របៀបរៀបរយតាមមណ្ឌលប្រលងនីមួយ ៗ ត្រូវអនុវត្តតាមភារកិច្ចរបស់ខ្លួនអោយបានហ្មត់ចត់ ត្រឹមត្រូវចាំបាច់ធ្វើអោយការងារប្រលងប្រព្រឹត្តទៅក្នុងប្រក្រតីភាព និង ប្រសិទ្ធភាព ចៀសវាង ដាច់ខាតការប្រព្រឹត្តអ្វីដែលធ្វើអោយខូចវិន័យ និងសណ្តាប់ធ្នាប់នៃការប្រលង ។

រាជរដ្ឋាភិបាលសង្ឃឹមយ៉ាងកក់ក្ដៅបំផុត ចំពោះក្រសួង សាលាខេត្ត ក្រុង ទាំងអស់ថា និង លើកកំពស់ឆន្ទៈអនុវត្តសារាចរណែនាំនេះអោយបានជោគជ័យ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឬទ្ធិ	**ហ៊ុន សែន**

* * *

III - ការងារបណ្ដាក្រសួង

១ - ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៦

ប្រកាសលេខ : ៣៥៩ បល.ប្រក

ស្ដីពីការផ្ទេរនិងតែងតាំងមន្ត្រីរាជការ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

- បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញច្បាប់ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ .
- បានឃើញ ប្រកាសលេខ ៧៧៤ ចត.ប្រក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៤ ត្រង់ប្រការ១ ចំណុចទី៣ ស្ដីពីការតែងតាំងលោក ហ៊ុន ប៊ុនថាង

ជាអនុប្រធានការិយាល័យបៀវត្ស ពលកម្ម នាយកដ្ឋាន បុគ្គលិក .

- បានឃើញ លិខិតលេខ ៨១/៩៦ ឧសក ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៩៦ របស់មន្ទីរឧស្សាហកម្មរ៉ែ និង ថាមពល ខេត្តរតនគីរី ស្តីពីសំណើសុំមន្ត្រី ០១ នាក់ ពីនាយកដ្ឋានបុគ្គលិកអោយ ទៅទទួលភារកិច្ចជាអនុប្រធានមន្ទីរ
- បានឃើញលិខិតសុំផ្លាស់ទៅបំរើការងារនៅមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តរតនគីរីរបស់លោក ហ៊ុន ប៊ុនថាន ចុះថ្ងៃទី ០៧/៥/៩៦
- ពិនិត្យសំណូមពរការងារចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : ផ្ទេរភារកិច្ច និងតែងតាំងលោក **ហ៊ុន ប៊ុនថាន** បច្ចុប្បន្នអនុប្រធានការិយាល័យ បៀវត្សពលកម្ម នាយកដ្ឋានបុគ្គលិក និង ជាសមាជិកក្រុមជំនួយការឯកឧត្តមរដ្ឋមន្ត្រី អោយទៅធ្វើជាអនុប្រធានមន្ទីរឧស្សាហកម្មរ៉ែ និងថាមពល ខេត្ត រតនគីរី ។

ប្រការ ២ : រាល់ប្រកាស កំណត់ចាត់ការដែលមានចំណុចពាក់ព័ន្ធ នឹង សាមីជនដូចមានចែងក្នុងប្រការ ១ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : លោកប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញកិច្ច ប្រធានមន្ទីរ ឧស្សាហកម្ម រ៉ែនិងថាមពលខេត្ត រតនគីរី និងលោក **ហ៊ុន ប៊ុនថាន** មាន ភារកិច្ចអនុវត្តក្នុងក្របខ័ណ្ឌសមត្ថកិច្ចរៀងៗ ខ្លួនតាមប្រកាសនេះ ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីកាលបរិច្ឆេទចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

* * *

២ - ផ្នែកការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៦

ប្រកាសលេខ: ១៨៥ ពណ.គន.ប្រក

ស្តីពីការប្រគល់ទីតាំងមណ្ឌលឃ្លាំងលេខ ១

រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាល ។
- បានឃើញកិច្ចសន្យាជួលទីតាំងមណ្ឌលឃ្លាំងលេខ ០១ នៅ គ.ម ៦ របស់ក្រុមហ៊ុន សំភារៈបរិក្ខារចុះថ្ងៃទី ១៤/៥/៩៦ រវាងក្រុមហ៊ុនសំភារៈបរិក្ខារនៃក្រសួងពាណិជ្ជកម្ម និង ក្រុមហ៊ុន PRESIDENT KNITTING & GARMENT C O. . LTD CAMBODIA តំណាងដោយលោក LEM LENG ។

សំរេច

ប្រការ ១ : ប្រគល់ការគ្រប់គ្រងទីតាំងមណ្ឌលឃ្លាំងលេខ ០១ នៅ គ.ម ៦ ក្នុងនោះរួមមានដីធ្លី និង ឃ្លាំង ដូចមានចែងក្នុងប្រការ ០១ នៃកិច្ចសន្យា ជូនក្រុមហ៊ុន PRESIDENT KNITTING & GARMENT C o. . LTD CAMBODIA ។

ប្រការ ២ : ក្រុមហ៊ុន PRESIDENT KNITTING & GARMENT Co., LTD CAMBODIA ត្រូវគោរពនិងអនុវត្តអោយបានល្អ តាមរាល់ប្រការដែល មានចែងក្នុងកិច្ចសន្យាចុះថ្ងៃទី ១៤ ឧសភា ១៩៩៦ និងច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានគណនេយ្យ–ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាន ក្រុមហ៊ុនសំភារៈបរិក្ខារ ត្រូវទទួលបន្ទុកអនុវត្តន៍ប្រកាសនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ចាប់ ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ចម ប្រសិទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៦

ប្រកាសលេខ : ១៨៦ ពណគន-ប្រក

ស្តីពីការប្រគល់ឃ្លាំងជូនម៉ៅ (កំពង់ចាម)

រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាល ។
- បានឃើញកំណត់ហេតុប្រគល់ ទទួលដីនិងសំបកឃ្លាំងជូនម៉ៅ «កំពង់ចាម » ចុះថ្ងៃទី ០៨ ឧសភា ៩៦ ។

សំរេច

ប្រការ ១ : ប្រគល់ការគ្រប់គ្រងទីតាំងដីនិងឃ្លាំង ដូនម៉ៅ ដែលមានទំហំបណ្តោយ 50 m ទទឹង 24 m កំពស់ 4.6 m ផ្ទៃដីសរុប 2 400 m2 ស្ថិតនៅតាមបណ្តោយផ្លូវលំមួយចំងាយ 2 Km ខាងត្បូងទីប្រជុំជន ផ្សារទន្លេបិទ ជូនទៅលោក **សុខ នី** ជាអ្នកគ្រប់គ្រងផ្ទាល់ដោយផ្តាច់ចេញពីការ គ្រប់គ្រងរបស់ក្រុមហ៊ុនកសិផល រុក្ខផល ។

ប្រការ ២ : លោក **សុខ នី** ត្រូវគោរពនិងអនុវត្តអោយបាននូវរាល់ប្រការផ្សេង ៗ នៃច្បាប់របស់រដ្ឋដើម្បី ធានាដល់សុវត្ថិភាព និងបរិដ្ឋានសង្គម ។

ប្រការ ៣ : ប្រធានមន្ទីរ , ប្រធាននាយដ្ឋានគណនេយ្យ–ហិរញ្ញវត្ថុ , ប្រធាននាយកដ្ឋានបុគ្គលិក , ប្រធានក្រុមហ៊ុនកសិផល–រុក្ខផល ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះអោយទទួលបានលទ្ធផលល្អប្រសើរ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ចម ប្រសិទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១៨៧ ពណគន.ប្រក

ស្តីពី

ការប្រគល់ដី និងឃ្លាំងបេតុង ត្រើយខាងកើត

កំពង់ចំលង អ្នកលឿង

រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

– បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ ព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាល ។
- បានឃើញ លិខិតលេខ ៧២០ សហវ.ទរ ចុះថ្ងៃទី ០១ មេសា ៩៦ របស់ក្រសួងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ ស្តីពីករណីសំណើសុំគោលការណ៍លក់ដី និងសំបកឃ្លាំងបេតុង នៅ អ្នកលឿង របស់មន្ទីរពាណិជ្ជកម្មខេត្តព្រៃវែង ។
- បានឃើញការអនុវត្តបែបបទប្រគល់-ទទួលដី និងឃ្លាំងបេតុង ត្រើយខាងកើតកំពង់ចំលងអ្នកលឿង រវាងមន្ទីរពាណិជ្ជកម្មខេត្តព្រៃវែង និង លោក នៅ សុខា ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៩៦ ។

សំរេច

ប្រការ ១ : ប្រគល់ការគ្រប់គ្រងទីតាំងដី និងឃ្លាំងបេតុង ដែលមាន : ទំហំដី : ៨០ម × ៦០ម និង ឃ្លាំងទំហំ ៥០ម × ៥០ម ស្ថិតនៅត្រើយខាងកើតកំពង់ចំលងអ្នកលឿង ក្នុងឃុំព្រែកខ្សាយ សង្កាត់ « ២ » ស្រុកពាមរក៍ ខេត្តព្រៃវែង ជូនទៅលោក **នៅ សុខា** កាន់អត្តសញ្ញាណ ប័ណ្ណលេខ : ១៥៧០០៧ ភព ចុះថ្ងៃទី ០៤ /១០/១៩៨៨ មានទីលំនៅ ផ្ទះលេខ ៣១ អឺ០ ផ្លូវ ១៤១ ក្រុម ៤៤ សង្កាត់អូរឫស្សី២ ខណ្ឌ៧មករា ក្រុងភ្នំពេញ ជាអ្នកគ្រប់គ្រងផ្ទាល់ដោយផ្តាច់ចេញពីមន្ទីរពាណិជ្ជកម្មខេត្តព្រៃវែង ។

ប្រការ ២ : លោក **នៅ សុខា** ត្រូវគោរព និងអនុវត្តអោយបាននូវរាលប្រការផ្សេង ៗ នៃ ច្បាប់របស់រដ្ឋ ដើម្បីធានាដល់សុវត្ថិភាពនិងបរិដ្ឋានសង្គម ។

ប្រការ ៣ : ប្រធានមន្ទីរនៃក្រសួង ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាន

នាយកដ្ឋានបុគ្គលិក ប្រធានមន្ទីរពាណិជ្ជកម្មខេត្តព្រៃវែង ត្រូវអនុវត្តប្រកាសនេះអោយទទួលបានលទ្ធផលល្អប្រសើរ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ចម ប្រសិទ្ធ

* * *

៣ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១៣៩ ពម.ចសឧ.ប្រក

រដ្ឋមន្ត្រី ក្រសួងពត៌មាន

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រម លេខ នសរកម/១០/៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពត៌មាន ។
- យោងលិខិតជូនដំណឹង របស់ក្រសួងពត៌មាន លេខ ១២២៤ /៩៤ /ពម ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ស្តីពីការបោះពុម្ពផ្សាយ
- យោងលិខិតស្នើសុំអនុញ្ញាតច្បាប់បើកអាជីវកម្មរោងពុម្ពឈ្មោះ «សុភមង្គល » របស់ លោក ខូវ - ស្រៀង ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតជូនលោក **ខូវ ស្រៀង** ទីលំនៅផ្ទះលេខ ១០៧ ផ្លូវលេខ ១៣៤ ក្រុមទី ៩ សង្កាត់ ផ្សារដេប៉ូ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ បើក

អាជីវកម្មរោងពុម្ព ដែល មានឈ្មោះ «សុភមង្គល» ទីតាំងស្ថិតនៅលំនៅស្ថានខាងលើ ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវអនុវត្តតាមកិច្ចសន្យា សមស្របទៅនឹងទំនៀមទំលាប់ សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសដូចមានចែងក្នុងប្រការ២ សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន ។

ប្រការ ៤ : នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ សោតទស្សន៍ នៃអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ប្រធានមន្ទីរពតិមាន រាជធានីភ្នំពេញ ត្រូវអនុវត្តតាមប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៥ : ប្រកាសនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ខៀវ កាញារីទ្ធ

* * *

៤ - ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៩៦

ប្រកាសលេខ : ៤១២ អយក.ប្រក

ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅសំរាប់គ្រូ

« គណិតវិទ្យាថ្នាក់ទី ១ »

* * *

រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស–រកត ១០៩៤–៩០ ចុះថ្ងៃ ៣១ ខែ តុលា ឆ្នាំ១៩៩៤ កែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានពិនិត្យលិខិតឧទ្ទេសនាម លេខ៣១៨ អយក.ឧទន. ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងអប់រំ ស្តីពីការបង្កើតគណៈកម្មការកែលំអប្រព័ន្ធអប់រំ
- បានពិនិត្យរបាយការណ៍របស់គណៈកម្មការ ពិនិត្យខ្លឹមសារគណិតវិទ្យា ចុះថ្ងៃ ទី ២៩ ខែ មេសា ឆ្នាំ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅសំរាប់គ្រូ «គណិតវិទ្យាថ្នាក់ទី ១» ដែលជាស្នាដៃនិពន្ធរបស់គណៈកម្មការគណិតវិទ្យា បឋមសិក្សា នៃវិទ្យាស្ថានស្រាវជ្រាវក្រសួងអប់រំ យុវជន និង កីឡា និងរៀបរៀងដោយ លោក **ចាន់ ពន** ដើម្បីប្រើប្រាស់នៅតាមសាលារៀន ចំណេះទូទៅ ។

ប្រការ ២ : មន្ទីរ នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការហិរញ្ញកិច្ច វិទ្យាស្ថានស្រាវជ្រាវ គ្រឹះស្ថាន បោះពុម្ពផ្សាយអប់រំ មជ្ឈមណ្ឌលចែកផ្សាយ បណ្ណាល័យ

នាយកដ្ឋានចំណេះទូទៅនិងមត្តេយ្យសិក្សា មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តុល ឡោះ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៩៦

ប្រកាសលេខ : ៤១៣ អយក.ប្រក

ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅសំរាប់គ្រូ

« ភាសាខ្មែរថ្នាក់ទី ១ »

រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស–រកត ១០៩៤–៩០ ចុះថ្ងៃ ៣១ ខែ តុលា ឆ្នាំ១៩៩៤ កែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានពិនិត្យលិខិតឧទ្ទេសនាម លេខ ៣១៨ អយក. ឧទន ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ១៩៩៥ របស់ក្រសួងអប់រំ ស្តីពីការបង្កើតគណៈកម្មការកែលំអប្រព័ន្ធអប់រំ

- បានពិនិត្យរបាយការណ៍របស់គណៈកម្មការ ពិនិត្យខ្លឹមសារភាសាខ្មែរ ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅសំរាប់គ្រូ « ភាសាខ្មែរថ្នាក់ទី ១ » ដែលជាស្នាដៃ និពន្ធរបស់គណៈកម្មការភាសាខ្មែរ បឋមសិក្សា នៃវិទ្យាស្ថានស្រាវជ្រាវក្រសួងអប់រំ យុវជន និង កីឡា និងរៀបរៀង ដោយ លោក **លី សុមុនី** ដើម្បីប្រើប្រាស់នៅតាមសាលារៀនចំណេះទូទៅ ។

ប្រការ ២ : មន្ទីរ នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការហិរញ្ញកិច្ច វិទ្យាស្ថានស្រាវជ្រាវ គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ មជ្ឈមណ្ឌលចែកផ្សាយ បណ្ណាល័យ នាយកដ្ឋានចំណេះទូទៅនិងមធ្យមសិក្សា មានភារកិច្ចអនុវត្តសេចក្ដីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តុល ឡោះ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៦

ប្រកាសលេខ : ៤១៦ អយក.ប្រក

ស្ដីពីការប្ដូរឈ្មោះ អនុវិទ្យាល័យ ក្រាំងយ៉ូវ ទៅជា « អនុវិទ្យាល័យ ហ៊ុន សែន ក្រាំងយ៉ូវ » ស្ថិតនៅឃុំ ស្រុកស្អាង ខេត្ត កណ្ដាល

រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១

វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំង រាជ រដ្ឋាភិបាលកម្ពុជា ។

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែល ប្រកាស អោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ។
- បានឃើញក្រឹត្យ ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ។
- យោងលិខិតរបស់គណៈកម្មការសាងសង់អនុវិទ្យាល័យ ក្រាំងយ៉ូវលេខ ៣០/ ៩៦ អនុវិ.ក្រយ៉ ចុះថ្ងៃទី ២៨ កុម្ភៈ ១៩៩៦ ដោយមានចំនារបញ្ជូនពីមន្ទីរអប់រំ យុវជន និង កីឡា និង អភិបាល ខេត្តកណ្តាល ។
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយប្តូរឈ្មោះ អនុវិទ្យាល័យ ក្រាំងយ៉ូវ ទៅជា « អនុវិទ្យាល័យ **ហ៊ុន សែន** ក្រាំងយ៉ូវ » ចាប់ពីឆ្នាំសិក្សា ១៩៩៥–៩៦ តទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋាន ចាត់តាំង ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និង កីឡា – ប្រធានមន្ទីរ អប់រំយុវជន និងកីឡាខេត្តកណ្តាល និងនាយកអនុវិទ្យាល័យ ហ៊ុន សែន ក្រាំងយ៉ូវ មានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តុល ឡោះ

* * *

៥ - ទីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៩៦

ប្រកាសលេខ : ៨៩ ប្រក.វវស.ម

ស្តីពីការបង្កើតគណៈកម្មាធិការបច្ចេកទេសរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ដើម្បីកែទំរង់រដ្ឋបាល

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតរាជ រដ្ឋាភិបាល ។
- យោងតាមលិខិតលេខៈ ២៦៧ សជណគបអ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៩៦ របស់ ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីសំណើរៀបចំគណៈកម្មការ បច្ចេកទេសកែទំរង់រដ្ឋបាល តាមក្រសួង និង រដ្ឋលេខាធិការដ្ឋាន ។

សំរេច

ប្រការ ១ : ត្រូវបានបង្កើតគណៈកម្មាធិការមួយឈ្មោះថា «គណៈកម្មាធិការបច្ចេកទេសរបស់ក្រសួង វប្បធម៌ និង វិចិត្រសិល្បៈដើម្បីកែទំរង់រដ្ឋបាល» ដែលជាចំណុចកណ្តាលរបស់ទីស្តីការគណៈ រដ្ឋមន្ត្រីសំរាប់ ÷

- ទំនាក់ទំនងជាមួយ គណៈកម្មាធិការអន្តរក្រសួង
- ដើម្បីពិគ្រោះពិភាក្សា និង សំរបសំរួលការងារបច្ចេកទេស អំពីការងារកែទំរង់រដ្ឋបាល ។

ប្រការ ២ : គណៈកម្មាធិការបច្ចេកទេស របស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ដើម្បីកែទំរង់រដ្ឋបាល មានសមាសភាពដូចតទៅ ÷

១-ឯកឧត្តម **នុត ណារ៉ាង** រដ្ឋមន្ត្រី ជាប្រធាន

២-អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិស៊ីរីវុធចំណរ៉ា** រដ្ឋលេខាធិការ ជាអនុប្រធាន

៣-ឯកឧត្តម **ម៉ែន យ៉េត** អនុរដ្ឋលេខាធិការ ជាអនុប្រធាន

៤-លោក **ស៊ុក ម៉ិនហុក** នាយខុទ្ទកាល័យ ជាសមាជិក

៥-លោក **ឈុម តួច** ប្រធាននាយកដ្ឋានរដ្ឋបាល ជាសមាជិក

៦-លោក **ថ្លាក់ គ្រួយ** ប្រធាននាយកដ្ឋានផែនការគណនេយ្យ ជាសមាជិក

៧-លោក **អ៊ុក សុជាតិ** អនុប្រធាននាយកដ្ឋានបុគ្គលិក ជាសមាជិក

ប្រការ ៣ : គណៈកម្មាធិការបច្ចេកទេសរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ដើម្បីកែទំរង់រដ្ឋបាល មានភារកិច្ចដូចតទៅ ÷

- សិក្សាស្រាវជ្រាវ វិភាគ និងលើកយោបល់លើការជ្រើសរើសយកការកែទំរង់នាយកដ្ឋានចំណុះ និងមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈគ្រប់ខេត្ត ក្រុង ជូនគណៈកម្មាធិការបច្ចេកទេសអន្តរក្រសួង ដើម្បីកែទំរង់រដ្ឋបាល ។
- ណែនាំ និងដំណើរការកម្មវិធីកែទំរង់
- ជំរុញ និងសំរបសំរួលនិងរៀបចំគ្រប់គ្រងការកែទំរង់របស់នាយកដ្ឋាន និងមន្ទីរ វប្បធម៌ និង វិចិត្រសិល្បៈគ្រប់ខេត្ត-ក្រុង ។
- តាមដាននិងវាយតម្លៃលើការអនុវត្តកម្មវិធីនៃការកែទំរង់របស់នាយកដ្ឋាន និង មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈគ្រប់ខេត្ត-ក្រុង ។
- ធ្វើអោយមានលក្ខណៈប្រសើរក្នុងការផ្សព្វផ្សាយទូលំទូលាយនូវពត៌មានដែលបានមកពី គណៈកម្មការបច្ចេកទេសអន្តរក្រសួងដើម្បីកែទំរង់រដ្ឋបាលដល់នាយកដ្ឋាន និងមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈគ្រប់ខេត្ត ក្រុង ។

ប្រការ ៤- : សមាជិកគណៈកម្មាធិការត្រូវចូលរួមប្រជុំ និងធ្វើការងារ តាមការអញ្ជើញ និងណែនាំរបស់ ប្រធាន ។

ប្រការ ៥ : គណៈកម្មាធិការបច្ចេកទេសរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈដើម្បីកែទំរង់រដ្ឋបាល ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់គណៈកម្មាធិការបច្ចេកទេស អន្តរក្រសួង ដើម្បីកែទំរង់រដ្ឋបាល និង មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ដើម្បីបំពេញការងាររបស់ខ្លួន ។

ប្រការ ៦ : គណៈកម្មាធិការនេះ មានលេខាធិការដ្ឋានមួយប្រចាំការនៅក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ជាជំនួយការ ដែលមានសមាសភាពដូចតទៅ ÷

១–លោក **ឡុង ឧត្តម** អគ្គនាយករងរដ្ឋបាល ប្រធាន

២–លោក **ឆិត អ៊ឹម** ប្រធាននាយកដ្ឋានបុគ្គលិក អនុប្រធានអចិន្ត្រៃយ៍

៣–លោក **ទឹម សុខុម** តំណាងនាយកដ្ឋានបុគ្គលិក ជាសមាជិក

៤–លោក **អន សារ៉ី** តំណាងនាយកដ្ឋានបុគ្គលិក ជាសមាជិក

៥–លោក **ស្រី សួន** តំណាងនាយកដ្ឋាន បុគ្គលិក ជាសមាជិក

ប្រការ ៧ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានបច្ចេកទេស គ្រប់អង្គភាពក្រោមឱវាទក្រសួង និង អស់លោកដែលមានរាយនាមចែងក្នុងប្រការ ២ ប្រការ៦ ត្រូវអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ឌុត ណារ៉ាង

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៨៦

ប្រកាសលេខ : ៩០ ប្រក.ខខស.ឬ

ស្តីពីការផ្ទេរបណ្ណាល័យជាតិ និងក្របខ័ណ្ឌមន្ត្រីរាជការ

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- យោងស្មារតីអង្គប្រជុំថ្នាក់ដឹកនាំក្រសួង ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៩៦ ។

សំរេច

ប្រការ ១ : ផ្ទេរបណ្ណាល័យជាតិដែលមានថ្នាក់ស្មើការិយាល័យ និង ក្របខ័ណ្ឌមន្ត្រីរាជការ ចំនួន២២ នាក់ ដូចមានរាយនាមខាងក្រោមនេះពីនាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌អោយមកស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានបោះពុម្ពផ្សាយវប្បធម៌ ការអាន និង តំកល់ឯកសារវិញ ÷

១– លោក **ឡុច ឈឿន** អនុប្រធាន ទទួលខុសត្រូវរួម

២–លោក **ហ៊ី ហ៊ិន** អនុប្រធាន

៣–កញ្ញា **រស់ សារូ** អនុប្រធាន

៤–លោក **អ៊ុម សុធារិទ្ធ** បុគ្គលិក

៥–លោក **សេខ ម៉េខ** –

៦–លោក **យ៉ូយ វិសាលមុនី** –

៧–លោក **ផេង ពងស្រ៊ាស៊ី** –

៨–លោក **គុណ វណ្ណា** –

៩–លោក **កួច សារិន** –

១០–លោក **សុខ សុផល** –

១១–លោក **អន ឡុំង** –

១២–លោក **អ៊ុន សំអឿន** ឆ្មាំអចិន្ត្រៃយ៍

១៣–អ្នកស្រី **ម៉ៅ ថាច** បុគ្គលិក

១៤–អ្នកស្រី **សួន សុខា** –

១៥–អ្នកស្រី **ឈុន មុនី** –

១៦–អ្នកស្រី **ច្រាក់ សុគាព** –

១៧–អ្នកស្រី **តាន់ សុម៉ាលី** –

១៨–អ្នកស្រី **ចាន់ ម៉ារីយ៉ាន** –

១៩–អ្នកស្រី **ចឹក ឡូច** –

២០–កញ្ញា **សួន សុគី** –

២១–កញ្ញា **ស៊ឹម មូនី** –

២២–លោក **ពេជ ថាលី** –

ប្រការ ២ : ផ្ទេរចលនទ្រព្យ និងអចលនទ្រព្យ របស់បណ្ណាល័យជាតិជូនទៅនាយកដ្ឋានបោះពុម្ពផ្សាយ ការអាន និងតំកល់ឯកសារ ។

ប្រការ ៣ : ប្រាក់បៀវត្ស និងរបបឧបត្ថម្ភផ្សេងៗរបស់សាមីខ្លួន ត្រូវបានផ្ទេរទៅ នាយកដ្ឋានបោះពុម្ពផ្សាយ ការអាន និងតំកល់ឯកសារ ។

ប្រការ ៤ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានបច្ចេកទេស នាយកដ្ឋានអភិវឌ្ឍន៍ វប្បធម៌ នាយកដ្ឋានបោះពុម្ពផ្សាយការអាន និងតំកល់ឯកសារព្រមទាំងសាមីខ្លួន មានភារកិច្ចអនុវត្តន៍ប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

នុត ណារ៉ាង

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៩៦

ប្រកាស

លេខ : ៩២ ប្រក.វវស.ប

ស្តីពីការបង្កើតគណៈកម្មការមេប្រយោគប្រឡងយកសញ្ញាបត្រ សិល្បៈ និង ស្នាតកបត្រសិល្បៈ ឆ្នាំ ១៩៩៥ - ៩៦

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- តាមសំណើរបស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

សំរេច

ប្រការ ១ : តែងតាំងគណៈកម្មការមេប្រយោគសំរាប់ការប្រឡងយកសញ្ញាប័ត្រសិល្បៈ និង ស្នាតកប័ត្រសិល្បៈ ឆ្នាំ សិក្សា ១៩៩៥ - ៩៦ ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ១៩៩៦ តទៅ ។

ប្រការ ២ : សមាសភាពគណៈកម្មការមេប្រយោគ រួមមាន :

១-អ្នកអគ្គម្ចាស់ **ស៊ីសុវត្ថិ ស៊ីរីវុធចំណាក់**	ប្រធាន
២-លោក **នុយ គឿន**	អនុប្រធាន
៣-លោក **ឡោ សាន**	អនុប្រធាន
៤-លោក **អ៊ុក សុជាតិ**	សមាជិក
៥-លោក **ចោ ឡឿង**	សមាជិក
៦-លោក **ព្រឿង ឈាង**	សមាជិក
៧-លោក **ទ៊ែន ផាត**	សមាជិក

៨- មន្ត្រីតំណាងក្រសួងអប់រំ យុវជននិងកីឡា សមាជិក

៩-លោក **ចាប សួន** សមាជិក

ប្រការ ៣ : ប្រធានគណៈកម្មការមេប្រយោគ មានសិទ្ធិបង្កើតអនុគណៈកម្មការ ឬក្រុមទាំងឡាយដែល ជាតម្រូវការចាំបាច់ក្នុងដំណើរការប្រឡង ។

ប្រការ ៤ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានបច្ចេកទេស សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ព្រមទាំងសាមីខ្លួន មានភារកិច្ចអនុវត្តន៍ប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

តុត ណារ៉ាង

* * *

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ៣០៩ រៀល